LCR ក្រុមមេធាវីការពារសិទ្ធិពលរដ្ឋ ក្រុងបូស្តុន

# ដំណោះស្រាយលើបណ្ដឹងអំពីសិទ្ធិបោះឆ្នោតថ្នាក់ជាតិ
# ប្ដឹងសាលាក្រុងឡូវែល ជំទាស់នឹងប្រព័ន្ធបោះឆ្នោត
# សំណួរទូទៅ

## <u>តើសំណុំរឿងនេះ និយាយអំពីអ្វី?</u>

កាលពីខែ ឧសភា ឆ្នាំ ២០១៧ ពលរដ្ឋចម្រុះពូជសាសន៍ នៅទីក្រុងឡូវែល រួមមានសហគមន៍ពលរដ្ឋអាមេរិកដើមកំណើតអាស៊ី និង ពលរដ្ឋអាមេរិកដើមកំណើតអាមេរិកឡាទីន និង អេស្ប៉ាញ បានដាក់បណ្ដឹងអំពីសិទ្ធិបោះឆ្នោតថ្នាក់ជាតិ ដោយប្ដឹងជំទាស់នឹងប្រព័ន្ធបោះឆ្នោត “មិនសមាមាត្រ” ក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុងទាំង ០៩ នាក់ និង សមាជិកគណៈកម្មាធិការសាលារៀនទាំង ០៦ នាក់។ បណ្ដឹងនោះចោទប្រកាន់ថា ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះ នាំឲ្យបដិសេធសិទ្ធិ ឬ ធ្វើឲ្យបាត់បង់សិទ្ធិបោះឆ្នោតរបស់ពលរដ្ឋសហគមន៍ ដើមកំណើតអាស៊ី និង អាមេរិកឡាទីន និង អេស្ប៉ាញ។ ទោះបីជាពលរដ្ឋសហគមន៍ដើមកំណើតទាំងនេះ មានចំនួនប្រហែល ៤៩% នៃចំនួនពលរដ្ឋសរុបនៅទីក្រុងឡូវែលក៏ដោយ មន្ត្រីជាប់ឆ្នោតក្នុងក្រុង មិនបានតំណាងឲ្យសំឡេង របស់សហគមន៍ទាំងនោះទាល់តែសោះ ពីយូរលង់ណាស់មកហើយ។

ដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ គឺតំណាងដោយក្រុមមេធាវីដើម្បីសិទ្ធិពលរដ្ឋ និង ក្រុមហ៊ុនមេធាវី Ropes & Gray។ សេវាមេធាវីនេះ មិនគិតប្រាក់ទេ។ សំណុំរឿងនេះមានឈ្មោះថា *ហួត និង អ្នកផ្សេងទៀត ទល់នឹង សាលាក្រុងឡូវែល និង អ្នកផ្សេងទៀត* (*Huot et al. v. City of Lowell et al.*, 17-cv-10895 (D. Mass. 2017)។

## <u>តើមានអ្វីកើតឡើងក្នុងសំណុំរឿងនេះ?</u>

សំណុំរឿងនេះ ត្រូវបានដាក់ពីដំបូងនៅសាលាដំបូងសហរដ្ឋអាមេរិក ប្រចាំរដ្ឋម៉ាសាឈូសេត កាលពីខែ ឧសភា ឆ្នាំ ២០១៧។

នៅខែ តុលា ឆ្នាំ ២០១៧ ចៅក្រមថ្នាក់ជាតិមួយរូប បានសម្រេចឱ្យបញ្ជូនសំណុំរឿងឱ្យចាត់ការបន្ត ដោយទាត់ចោលការអះអាងរបស់សាលាក្រុង ដែលថាដើមបណ្ដឹងជាពលរដ្ឋអាមេរិកដើមកំណើតអាមេរិកឡាទីន/អេស្ប៉ាញ និង ពលរដ្ឋអាមេរិកដើមកំណើតអាស៊ី គ្មានសិទ្ធិរួមគ្នាដាក់បណ្ដឹងប្រឆាំងសាលាក្រុងនោះ។ សំណុំរឿងបានដំណើរការដល់ដំណាក់កាល មុនអង្គសេចក្ដី ដែលគូភាគីទាំងសងខាង អាចដាក់សំណើសុំឯកសារភស្តុតាង និង សក្ខីកម្មពីគ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្ដឹង។

នៅដើមខែ ធ្នូ ឆ្នាំ ២០១៨ គូភាគីក្នុងរឿងក្ដី បានឈានចូលដំណាក់កាលសម្រុះសម្រួលគ្នា ដោយមានមន្ត្រីថ្នាក់ជាតិមួយរូប ធ្វើជាអ្នកសម្របសម្រួល។ ក្នុងរយៈពេល ០៥ ខែក្រោយមក ការជួបសម្រុះសម្រួលគ្នានេះ បានប្រព្រឹត្តទៅជាច្រើនដង និង ធ្វើដោយសម្ងាត់។

នៅខែ ឧសភា ឆ្នាំ ២០១៩ ភាគីដើមបណ្ដឹង និង ភាគីចុងបណ្ដឹង បានប្រកាសថា ពួកគាត់បានឈានដល់ចំណុចដំណោះស្រាយមួយ ជាទម្រង់នៃសេចក្ដីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នា។ គូភាគីក្នុងរឿងក្ដីបានដាក់សំណើរួមគ្នាមួយ ស្នើសុំការយល់ព្រមពីចៅក្រម ទៅលើសេចក្ដីសម្រេចសម្រុះសម្រួលគ្នានោះ។ តុលាការត្រូវតែចេញសេចក្ដីសម្រេចមួយ ដើម្បីយល់ព្រមតាមសេចក្ដីសម្រេចសម្រុះសម្រួលគ្នានោះ ទើបដំណោះស្រាយនោះ មានប្រសិទ្ធភាពអនុវត្ត។

**<u>តើសាលាក្រុង នឹងត្រូវធ្វើយ៉ាងដូចម្ដេច ចំពោះសេចក្ដីសម្រេចសម្រុះសម្រួលគ្នានេះ ពេលតុលាការឯកភាពតាម?</u>**

សេចក្ដីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នានេះ នឹងតម្រូវឱ្យសាលាក្រុងផ្លាស់ប្ដូរប្រព័ន្ធបោះឆ្នោតរបស់ខ្លួន ដោយចាប់ផ្ដើមអនុវត្ត ពីការបោះឆ្នោតក្រុងនៅឆ្នាំ ២០២១ តទៅ។ សេចក្ដីសម្រេចនេះ ដាក់ចេញនូវជម្រើសប្រព័ន្ធបោះឆ្នោតចំនួន ០៦ ដែលសាលាក្រុងអាចជ្រើសរើសបាន។ ជម្រើសទាំងអស់នោះ សុទ្ធតែត្រូវបានគូភាគីនៃរឿងក្ដី យល់ស្របគ្នា ថាអនុលោមតាមច្បាប់ជាតិស្ដីពីសិទ្ធិបោះឆ្នោត។ សាលាក្រុងត្រូវតែជ្រើសជម្រើស ដែលព្រមព្រៀងគ្នារួចមួយ ជាដាច់ខាត។

សាលាក្រុងនឹងត្រូវពិនិត្យ និង វិភាគជម្រើសដែលព្រមព្រៀងគ្នានោះ នៅប៉ុន្មានខែខាងមុខទៀត តាមរយៈដំណើរការជាសាធារណៈមួយ ដែលនឹងអនុញ្ញាតឱ្យសហគមន៍ ចូលរួមបញ្ចេញមតិ ហើយនឹងត្រូវរៀបចំយុទ្ធនាការអប់រំជាសាធារណៈ ដោយធ្វើជាច្រើនភាសាផង។

ក្រុមប្រឹក្សាក្រុង អាចបង្រួមជម្រើសទាំងនោះ ឲ្យមកនៅសល់ត្រឹមជម្រើសចុងក្រោយចំនួន ០២ ដែលត្រូវដាក់ក្នុងសន្លឹកឆ្នោត នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៨ នេះ។ ប៉ុន្តែ ជម្រើសចុងក្រោយទាំងពីរនោះ មិនត្រូវកំណត់ក្នុងច្បាប់ នៅឡើយទេនៅពេលនោះ។ ប្រសិនបើសាលាក្រុងសម្រេចយកជម្រើសទាំងនេះ ដាក់ចូលក្នុងសន្លឹកឆ្នោតនៅក្រោយការបោះឆ្នោតនៅខែ វិច្ឆិកា ឆ្នាំ ២០១៨ សាលាក្រុងនឹងត្រូវសម្រេចជ្រើសរើសយកជម្រើសមួយចុងក្រោយ ក្នុងចំណោមជម្រើសទាំងពីរនោះ។

ជម្រើសមួយផ្សេងទៀត សាលាក្រុងអាចសម្រេចមិនដាក់បញ្ចូលបញ្ហានេះ នៅក្នុងសន្លឹកឆ្នោត ប៉ុន្តែសម្រេចជ្រើសរើសយកប្រព័ន្ធបោះឆ្នោតថ្មីមួយ ដោយផ្ទាល់តែម្តង។ បើដូច្នេះមែន ក្រុមប្រឹក្សាក្រុង ត្រូវជ្រើសប្រព័ន្ធបោះឆ្នោតថ្មីនេះ នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៨។

ទោះប្រព័ន្ធបោះឆ្នោតថ្មី ត្រូវសាលាក្រុងសម្រេចជ្រើសរើសរបៀបណានោះទេ នៅទីបំផុតសាលាក្រុងត្រូវតែរៀបចំយុទ្ធនាការអប់រំអ្នកបោះឆ្នោតទូទៅ ជាសាធារណៈ និង ច្រើនភាសា ដើម្បីឲ្យអ្នកបោះឆ្នោត បានយល់ដឹងអំពីប្រព័ន្ធបោះឆ្នោតថ្មីនេះ។

**តើសាលាក្រុង អាចជ្រើសយកជម្រើសនៃប្រព័ន្ធបោះឆ្នោតណាខ្លះ?**

សេចក្តីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នានេះ តម្រូវឲ្យសាលាក្រុងជ្រើសយកជម្រើសនៃប្រព័ន្ធបោះឆ្នោតមួយ ក្នុងចំណោមប្រព័ន្ធបោះឆ្នោតដូចខាងក្រោម។ ក្នុងប្រព័ន្ធបោះឆ្នោតនីមួយៗ ចំនួននៃសមាជិកក្រុមប្រឹក្សាក្រុង (ប្រាំបួន) និង ចំនួនសមាជិកនៃគណៈកម្មាធិការសាលារៀន (ប្រាំមួយ) នឹងនៅរក្សាដដែល លើកលែងតែមានបញ្ជាក់ផ្សេង ដូចខាងក្រោម។

- **ប្រព័ន្ធសមាជិកម្នាក់ប្រចាំស្រុកមួយ**– ក្នុងប្រព័ន្ធនេះ សាលាក្រុងត្រូវចែកចេញជា ០៩ ស្រុក ដោយស្រុកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសតំណាងម្នាក់ នៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាក្រុងទាំង ០៩ នាក់។ យ៉ាងហោចណាស់ មានស្រុកចំនួនពីរ នឹងចាត់ថ្នាក់ជាស្រុកដែលមានចំនួន "ជនជាតិភាគតិចមានសំឡេងភាគច្រើន" (ដោយកំណត់ថាជាស្រុកមួយ ដែលមានជនជាតិអាមេរិកដើមកំណើតអាស៊ី និង ជនអាមេរិកដើមកំណើតអាមេរិកឡាទីន/អេស្ប៉ាញ មានចំនួនភាគច្រើន ក្នុងចំណោមពលរដ្ឋដែលគ្រប់អាយុបោះឆ្នោត)។

សម្រាប់ការបោះឆ្នោតគណៈកម្មាធិការសាលារៀន ស្រុកទាំង ០៩ នឹងត្រូវបូកបញ្ចូលគ្នា ដើម្បីបង្កើតបានជាស្រុកធំចំនួន ០៣ ដោយបណ្តុំនៃស្រុកបីនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសសមាជិក ០២ រូបក្នុងចំណោមសមាជិកទាំង ០៦ រូបក្នុងគណៈកម្មាធិការសាលា រៀន។ យ៉ាងហោចណាស់ ក្នុងបណ្តុំនៃស្រុកបីណាមួយនោះ នឹងតំណាងឲ្យសហគមន៍ជនជាតិភាគតិចដែលមានសំឡេងភាគច្រើន។

- **<u>ប្រព័ន្ធចម្រុះ ៨-១</u>**– ក្នុងប្រព័ន្ធនេះ នឹងមាន ០៨ ស្រុក ដោយស្រុកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាម្នាក់ ក្នុងចំណោមក្រុមប្រឹក្សាក្រុងទាំង ០៩ នាក់។ យ៉ាងហោចណាស់ ស្រុកចំនួន ០២ នឹងក្លាយជាស្រុកដែលមានតំណាងជនជាតិភាគតិច ដែលមានសំឡេងភាគច្រើន។ ចំណែកឯសមាជិកក្រុមប្រឹក្សាក្រុងម្នាក់ នឹងត្រូវបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធមិនសមាមាត្រ។ សម្រាប់ការបោះឆ្នោតគណៈកម្មាធិការសាលារៀន នឹងមានស្រុកចំនួន ០៤ ដោយស្រុកនីមួយៗត្រូវបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការសាលារៀនមួយរូប ក្នុងចំណោម ០៦ រូប។ យ៉ាងហោចណាស់មានស្រុកមួយ ក្នុងចំណោមស្រុកទាំងនេះ នឹងមានតំណាងឲ្យជនជាតិភាគតិច ដែលមានសំឡេងភាគច្រើន។ សមាជិកគណៈកម្មាធិការសាលារៀន ០២ រូបទៀត នឹងត្រូវបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធមិនសមាមាត្រ។

- **<u>ប្រព័ន្ធចម្រុះ ៨-៣</u>**–ប្រព័ន្ធនេះ ដូចគ្នានឹងប្រព័ន្ធចម្រុះ ៨-១ ដែរ ខុសគ្នាត្រង់ថា ក្រុមប្រឹក្សាក្រុង នឹងត្រូវពង្រីកចំនួនបន្ថែមដល់ ១១ រូប ក្នុងនោះសមាជិកក្រុមប្រឹក្សាក្រុង ០៣ រូប ត្រូវបោះឆ្នោតតាមប្រព័ន្ធមិនសមាមាត្រ។

- **<u>ប្រព័ន្ធចម្រុះ ៧-២</u>**– ក្នុងប្រព័ន្ធនេះ នឹងមានស្រុកចំនួន ០៧ ដោយស្រុកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសសមាជិក ០១ រូប ក្នុងចំណោមសមាជិកទាំង ០៩ រូបនៃក្រុមប្រឹក្សាក្រុង។ យ៉ាងហោចណាស់មានស្រុកចំនួន ០២ នឹងមានតំណាងឲ្យជនជាតិភាគតិច ដែលមានសំឡេងភាគច្រើន។ ចំណែកឯសមាជិកក្រុមប្រឹក្សាក្រុងពីររូបទៀត នឹងត្រូវបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធមិនសមាមាត្រ។ សម្រាប់គណៈកម្មាធិការសាលារៀន ចំនួនសមាជិកនឹងបង្កើនដល់ ០៧ រូប ដោយសមាជិកមួយរូប នឹងត្រូវបោះឆ្នោតជ្រើសរើស ចេញពីស្រុកនីមួយៗ ក្នុងចំណោមស្រុកទាំង ០៧ នោះ។

- **<u>បោះឆ្នោតតាមជម្រើសចំណាត់ថ្នាក់</u>**– ក្នុងប្រព័ន្ធនេះ បេក្ខជនទាំងអស់ ដែលឈរឈ្មោះសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាក្រុង និង គណៈកម្មាធិការសាលារៀន ត្រូវបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធមិនសមាមាត្រ (នៅទូទាំងក្រុង)។ ប៉ុន្តែ អ្នកបោះឆ្នោតដាក់ចំណាត់ថ្នាក់ឲ្យបេក្ខជនឈរឈ្មោះ សម្រាប់ក្រុមប្រឹក្សាក្រុង និង គណៈកម្មាធិការសាលារៀន ទៅតាមលំដាប់លេខរៀងនៃការពេញចិត្ត (ឧទាហរណ៍ ១, ២, ៣, ៤, ។ល។)។ សន្លឹកឆ្នោតនឹងត្រូវរាប់តាមរបៀបការបោះឆ្នោតតាមជម្រើសចំណាត់ថ្នាក់ ដូចអ្វីដែលមានអនុវត្តនៅក្រុង Cambridge រដ្ឋម៉ាសាឈូសេត និង ក្រុង Minneapolis រដ្ឋមីនីសូតា។

- **<u>បោះឆ្នោតតាមជម្រើសចំណាត់ថ្នាក់បីស្រុក</u>**– ក្នុងប្រព័ន្ធនេះ ស្រុកចំនួន ០៣ នឹងត្រូវបង្កើតឡើង ដោយអ្នកបោះឆ្នោតក្នុងស្រុកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសបេក្ខជនចំនួន ០៣ រូបសម្រាប់ក្រុមប្រឹក្សាក្រុង និង ០២ រូបសម្រាប់គណៈកម្មាធិការសាលារៀន បោះឆ្នោតតាមជម្រើសចំណាត់ថ្នាក់។

## <u>តើសាលាក្រុង នៅតែមានការបោះឆ្នោតបឋមដដែលឬ?</u>

សម្រាប់ជម្រើសនៃការបោះឆ្នោតតាមជម្រើសចំណាត់ថ្នាក់ណាមួយ សាលាក្រុងនឹងមានជម្រើសក្នុងការលុបបំបាត់ការបោះឆ្នោតបឋមនេះ។ ការបោះឆ្នោតតាមជម្រើសចំណាត់ថ្នាក់ ជួនកាលគេឲ្យឈ្មោះថា "ការបោះឆ្នោតរើសបេក្ខជនតែមួយ" ឬ "single transferrable vote" ឬ "instant runoff," ដែលមិនចាំបាច់ឲ្យមានការបោះឆ្នោតបឋម ព្រោះវាអនុញ្ញាតឲ្យអ្នកបោះឆ្នោត ជ្រើសរើសបេក្ខជនច្រើននាក់ នៅលើសន្លឹកឆ្នោតតែមួយ។

សម្រាប់ជម្រើសផ្សេងទៀត សាលាក្រុងបន្តគោលការណ៍បោះឆ្នោតបឋម ឲ្យនៅដដែល (ដែលតម្រូវឲ្យរៀបចំការបោះឆ្នោតបឋម ដើម្បីជម្រុះបេក្ខជន ប្រសិនបើចំនួនបេក្ខជន មានច្រើនលើសពីរដងនៃចំនួនអាសនៈសម្រាប់ការបោះឆ្នោត)។ គោលការណ៍បោះឆ្នោតបឋមនេះ ត្រូវបន្តអនុវត្តយ៉ាងហោចណាស់ រហូតដល់ឆ្នាំ ២០២៣។ ក្រោយឆ្នាំ ២០២៣ សាលាក្រុងអាចកែប្រែគោលការណ៍បោះឆ្នោតបឋមនេះបាន ឲ្យតែការកែប្រែនោះ មិនត្រូវប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ម្ចាស់ឆ្នោត ជាជនជាតិអាមេរិកដើមកំណើតអាមេរិកឡាទីន/អេស្ប៉ាញ និង ជនជាតិអាមេរិកដើមកំណើតអាស៊ី។

**តើខណ្ឌសីមារបស់ស្រុក ត្រូវបែងចែកយ៉ាងដូចម្ដេច បើជ្រើសរើសយកប្រព័ន្ធបោះឆ្នោតតាមស្រុក?**

ប្រសិនបើប្រព័ន្ធបោះឆ្នោតតាមស្រុកណាមួយ ត្រូវគេជ្រើសរើសយក សាលាក្រុងត្រូវជួលអ្នកជំនាញឯករាជ្យ ដែលនឹងត្រូវសម្រេចថាតើស្រុកនីមួយៗ ត្រូវមានព្រំដែនសីមាត្រឹមណា។ អ្នកជំនាញនោះ ត្រូវតែមានការយល់ព្រមពីភាគីទាំងសងខាង ទាំងភាគីដើមបណ្ដឹង និង ចុងបណ្ដឹង។ ខាងដើមបណ្ដឹង ត្រូវទទួលបានទិន្នន័យ ការវិភាគ និង ផែនទីព្រាងរបស់ស្រុក ដែលអ្នកជំនាញបានគូសវាស និង ត្រូវមានសិទ្ធិជួប និង ផ្ដល់មតិទៅអ្នកជំនាញនោះ នៅក្នុងអំឡុងពេលនៃការគូសវាសព្រំដែនសីមាស្រុកទាំងនោះ។

**តើធ្វើដូចម្ដេច ប្រសិនបើសាលាក្រុង អត់ព្រមធ្វើតាមកិច្ចព្រមព្រៀងនោះ?**

សេចក្ដីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នានេះ ចែងថា តុលាការនៅតែមានយុត្តាធិការលើសំណុំរឿងនេះ ដោយតុលាការនៅតែមានអំណាចបង្គាប់ឲ្យសាលាក្រុងអនុវត្តតាម។

**តើគេកំណត់ពេលវេលា សម្រាប់ការអនុវត្តយ៉ាងដូចម្ដេច?**

- សំណើរួមគ្នា ត្រូវបានដាក់នៅតុលាការ នៅខែ ឧសភា ឆ្នាំ ២០១៩។
- សំណើរួមគ្នានេះ ត្រូវបានចាត់ការដោយតុលាការ (ឧទាហរណ៍ តុលាការឯកភាពលើសេចក្ដីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នា) – តុលាការនឹងកំណត់កាលបរិច្ឆេទនេះ។
- រយៈពេលត្រួតពិនិត្យ សម្រាប់សាលាក្រុង ក្នុងការសិក្សា និង វិភាគទៅលើជម្រើសនៃប្រព័ន្ធបោះឆ្នោត ដែលភាគីបានព្រមព្រៀងគ្នា– ក្នុងរយៈពេលបីខែ គិតចាប់ពីពេលដែលតុលាការ ឯកភាពលើសេចក្ដីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នានេះ។
- យុទ្ធការអប់រំសាធារណៈជាច្រើនភាសា អំពីជម្រើសនៃប្រព័ន្ធបោះឆ្នោត ដែលភាគីបានព្រមព្រៀងគ្នា–ស្របគ្នាទៅនឹងរយៈពេលត្រួតពិនិត្យ។

| បើមានការផ្តួចផ្តើមបញ្ចូលក្នុងសន្លឹកឆ្នោត | ឬ | បើគ្មានការផ្តួចផ្តើមបញ្ចូលក្នុងសន្លឹកឆ្នោត |
|---|---|---|
| ប្រព័ន្ធបោះឆ្នោតពីរ ដែលសម្រាំងចុងក្រោយគេ ដាក់ក្នុងសន្លឹកឆ្នោត (មិនកំណត់ក្នុងច្បាប់) ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩។ | | ថ្ងៃដែលក្រុមប្រឹក្សាក្រុង ជ្រើសរើសយកជម្រើសពីរ ដាក់ក្នុងសន្លឹកឆ្នោត នៅខែ វិច្ឆិកា ឆ្នាំ ២០១៩ បើសាលាក្រុងសម្រេចយកជម្រើសនេះ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩។ |
| ក្រុមប្រឹក្សាក្រុង សម្រេចជ្រើសយកប្រព័ន្ធបោះឆ្នោតថ្មី ដើម្បីអនុវត្តនៅឆ្នាំ ២០២១ ដោយសម្រេចត្រឹមថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៩។ | | ថ្ងៃដែលក្រុមប្រឹក្សាក្រុង ជ្រើសរើសយកប្រព័ន្ធបោះឆ្នោតថ្មី បើសាលាក្រុងសម្រេចមិនដាក់ប្រព័ន្ធនេះ នៅក្នុងសន្លឹកឆ្នោត– ថ្ងៃទី ០១ ខែ តុលាឆ្នាំ ២០១៩។ |
| ក្រុមប្រឹក្សាក្រុងដាក់សំណើច្បាប់សុំអនុវត្តប្រព័ន្ធបោះឆ្នោតថ្មី ត្រឹមថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៩។ | | ក្រុមប្រឹក្សាក្រុង ដាក់សំណើច្បាប់ សុំអនុវត្តប្រព័ន្ធបោះឆ្នោតថ្មី– ត្រឹមថ្ងៃទី ១៦ ខែ តុលាឆ្នាំ ២០១៩។ |

- តែងតាំងអ្នកជំនាញឯករាជ្យ (ប្រសិនបើជ្រើសរើសយកប្រព័ន្ធបោះឆ្នោតតាមស្រុក) និងត្រូវគូសបន្ទាត់ខណ្ឌសីមាដំបូងរបស់ស្រុក– ចុងឆ្នាំ ២០១៩- ដើមឆ្នាំ ២០២០។
- ចុងក្រោយបន្ទាត់ខណ្ឌសីមាស្រុក ត្រូវបានគូសរួច (ប្រសិនបើជ្រើសរើសយកប្រព័ន្ធបោះឆ្នោតតាមស្រុក) ដោយផ្អែកលើលទិន្នន័យជំរឿនឆ្នាំ ២០២០ (បើមាន) – ដើមឆ្នាំ ២០២១។
- យុទ្ធនាការអប់រំសាធារណៈជាច្រើនភាសា អំពីប្រព័ន្ធបោះឆ្នោតថ្មី– ឆ្នាំ ២០២០-ឆ្នាំ ២០២១។
- ការបោះឆ្នោតដំបូង ដោយប្រើប្រព័ន្ធបោះឆ្នោតថ្មី– ខែ វិច្ឆិកា ឆ្នាំ ២០២១។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមឯណាបាន ជុំវិញសំណុំរឿងនេះ?

ឯកសារយោងអំពីសំណុំរឿងនេះ និង ឯកសារច្បាប់ឯទៀត រួមទាំងសំណើស្តីពីសេចក្តីសម្រេចសម្រុះសម្រួលដោយការស្រុះស្រួលគ្នានេះផង អាចរកបាននៅលើគេហទំព័ររបស់មេធាវីដើម្បីសិទ្ធិពលរដ្ឋ តាមអាសយដ្ឋាន www.lawyersforcivilrights.org (សូមសរសេរពាក្យ “Lowell” នៅក្នុងកន្លែង search)៕